ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
នាយកដ្ឋានផែនការ ត្រួតពិនិត្យ តាយតម្លៃ និងស្រាវជ្រាវ

# កំណត់ហេតុកិច្ចប្រជុំថ្នាក់ដឹកនាំ
# អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែតុលា ឆ្នាំ២០២២

## ១. សេចក្តីផ្តើម

នៅថ្ងៃពុធ ៩កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែតុលា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តមអនុប្រធាន ឯកឧត្តមទីប្រឹក្សា នាយកខុទ្ទកាល័យ ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានទាំងបួន។

កិច្ចប្រជុំដំណើរការតាមរបៀបវារៈដូចខាងក្រោម ៖

១) មតិបើកអង្គប្រជុំ និងបើកកម្មវិធីដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២) បទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣) បទបង្ហាញស្តីពីក្របខណ្ឌនៃបទអន្តរាគមន៍សម្រាប់បញ្ចប់អេដស៍នៅកម្ពុជា បង្ហាញដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផល** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤) អនុសាសន៍ណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ២. ដំណើរការ និងមតិពិភាក្សានៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី បានបើកកិច្ចប្រជុំ និងមានមតិស្វាគមន៍ដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំប្រចាំខែ ដោយផ្ទាល់ និងតាមប្រព័ន្ធនិមិត្ត និងអនុញ្ញាតដល់ ឯកឧត្តមបណ្ឌិតអគ្គលេខាធិការ ធ្វើបទបង្ហាញពីរបាយការណ៍ប្រចាំខែតុលា ។

**ក) ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត អគ្គលេខាធិការ** បានធ្វើសេចក្តីរាយការណ៍ពីសកម្មភាព និងលទ្ធផលនានា របស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

នៅក្នុងបទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំ បានឆ្លុះបញ្ចាំងពីសកម្មភាពដ៏មមាញឹករបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តមអនុប្រធាន ក៏ដូចជាសកម្មភាព និងលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន និងផែនការសកម្មភាពបន្ទាប់ ដោយផ្តោតទៅលើការត្រៀមរៀបចំកិច្ចប្រជុំពេញអង្គលើកទី២ សន្និបាតប្រចាំឆ្នាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២២។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសកម្មភាពដ៏មមាញឹករបស់ ឯកឧត្តមក្នុងខែតុលា ក្នុងការចូលរួមសកម្មភាពអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅតាមបណ្តាខេត្តមួយចំនួនដែលទទួលរងគ្រោះដោយសារទឹកជំនន់កន្លងមក ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់ពីការបង្រៀនដល់សិស្សបរទេសរបស់ **ឯកឧត្តម** នៅក្នុងព្រឹត្តិការណ៍ Distinguished Annual Foreign Policy Lecture ក្រោមប្រធានបទ Cambodian and Her Place in Regional Geopolitics ដែលសម្របសម្រួលដោយលោក Harish C. Mehta ។ លោក Harish C. Mehta គាត់ជាអ្នកសរសេរសៀវភៅស្តីពីបុរសខ្លាំងនៅកម្ពុជា **សម្តេចតេជោ ហ៊ុន សែន**។ ជាទូទៅអ្នកដែលត្រូវបានអញ្ជើញចូលរួមឱ្យធ្វើបទបង្ហាញសុទ្ធតែជាអ្នកល្បីៗមកពីជុំវិញពិភពលោក ដែលមានបទពិសោធន៍ខាងភូមិសាស្ត្រនយោបាយ និងការដឹកនាំ។ បទបង្ហាញរបស់ឯកឧត្តមប្រធានមានការចាប់អារម្មណ៍ខ្លាំងពីអ្នកចូលរួម ព្រោះបទបង្ហាញមានរយៈពេល៤០នាទី តែរយៈពេលសំណួរ និងចម្លើយមានរហូតដល់រយៈពេល៤០នាទីដែរ បើទោះបីជាគេបានអនុញ្ញាតតែរយៈពេល២០នាទីក៏ដោយ។ ឯកឧត្តមបានគូសបញ្ជាក់ពីចំណុច៤សំខាន់ដែលខ្មែរមានជាពិសេសជាងគេគឺ ១) នៅសតវត្សទី៧ នៅតំបន់អាស៊ីប៉ាស៊ីហ្វិច ប្រទេសខ្មែរជាប្រទេសដែលមានវិសាលភពធំជាងគេ ២) ដែនដីសុវណ្ណភូមិគឺជាប្រទេសខ្មែរ ដែលមានភស្តុតាងបញ្ជាក់ក្នុងសិលាចារឹកនៅវត្តគីរីសាគរ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ៣) អំបូរខ្មែរមានឈាមពិសេសគឺអេម៉ូក្លូប៊ីនអី ៤) ខ្មែរជាអ្នករកឃើញលេខសូន្យមុនគេ ក្នុងអំឡុងឆ្នាំ៦៨៣ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីការងារផ្តល់ប័ណ្ណសមធម៌ (ID Poor) ជាកិច្ចការសំខាន់ដែលយើងត្រូវយកចិត្តទុកដាក់ ដោយបច្ចុប្បន្នមានចំនួនអ្នកផ្ទុកមេរោគអេដស៍ប្រហែលតែ៦០០០នាក់ប៉ុណ្ណោះដែលបានទទួលប័ណ្ណនេះ គឺមានប្រហែលតែ១០% ដោយមូលហេតុនៃការរក្សាការសម្ងាត់ (Confidentiality) ដែលបានរារាំងដល់ការទទួលបានប័ណ្ណនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថាដោយសារផលប៉ះពាល់នៃជំងឺកូវីដ ១៩ ដែលបានធ្វើឱ្យកម្ពុជាលែងក្លាយជាប្រទេសស្ថិតនៅកម្រិតខ្ពស់ក្នុងការឆ្លើយតបអេដស៍តទៅទៀត ហើយដើម្បីឈានទៅជាប្រទេសស្ថិតនៅកម្រិតខ្ពស់ក្នុងការឆ្លើយតបអេដស៍វិញ យើងត្រូវតែខិតខំក្នុងកាត់បន្ថយការឆ្លងមេរោគថ្មីឱ្យ

បានជាអតិបរមា ដោយការបង្កើនសកម្មភាពការងារបង្ការមេរោគអេដស៍។ ទាក់ទងនឹងការងារខាងលើ **ឯកឧត្តម** បានគោរពស្នើទៅ **សម្តេចតេជោ** និងបានទទួលការយល់ព្រមក្នុងការរៀបចំគោលនយោបាយបញ្ចប់អេដស៍នៅឆ្នាំ២០២៥។ ចំពោះក្រុមការងារដែលត្រូវរៀបចំគោលនយោបាយបញ្ចប់អេដស៍នៅឆ្នាំ ២០២៥ ត្រូវមាន៖

- តំណាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធាន
- តំណាងក្រសួងសុខាភិបាល ជាអនុប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានប្រគល់ការងារដល់ ឯកឧត្តមអគ្គលេខាធិការ ក្នុងការពិនិត្យមើលថា តើក្រសួង ស្ថាប័នណាខ្លះដែលត្រូវចូលជាសមាជិកក្រុមការងារនេះ ។ ចំពោះគោលនយោបាយនេះ ត្រូវតែបញ្ចប់ឱ្យបានមុនពេលបោះឆ្នោតតំណាងរាស្ត្រនៅឆ្នាំក២០២៣ ហើយក្រៅពីនេះ ត្រូវមានក្រុមស្នូលមួយទៀតដែលជាអ្នកលើកជាគោលគំនិត រៀបចំរបៀបវារៈ និងធ្វើសេចក្តីព្រាងឯកសារជាមុនសម្រាប់ការពិភាក្សា ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានប្រគល់ជូន ឯកឧត្តមវេជ្ជបណ្ឌិត ហោ ប៊ុនឡេង ជាអ្នកដឹកនាំក្រុមការងារស្នូលដោយសារតែគាត់ជាអ្នកមានគំនិតផ្តួចផ្តើមលើការងារនេះ ។

**ខ) បទបង្ហាញរបស់ ឯកឧត្តម ឌា ផលា ស្តីពីក្របខណ្ឌនៃបទអន្តរាគមន៍សម្រាប់បញ្ចប់អេដស៍នៅកម្ពុជា៖**

**ឯកឧត្តមអនុប្រធាន** បានគូសបញ្ជាក់ថា ការងារយើងគឺ ត្រូវបញ្ចប់អេដស៍ តែយើងនៅមានបញ្ហាខ្វះធនធាន ។ ដើម្បីសម្រេចការងារខាងលើបានត្រូវមានការជាប់ទាក់ទងនឹង ១) ការប្រើប្រាស់ទិន្នន័យ ២) ការសម្របសម្រួលយន្តការដែលមានស្រាប់របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដូចជា កិច្ចប្រជុំពេញអង្គ ក្រុមក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ. ក្រុមការងារ GDJ-TWG on HIV ក្រុមការងារយុទ្ធសាស្ត្រទាំង៥ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ៣) ការងារត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ។

ចំពោះការកាត់បន្ថយករណីឆ្លងមេរោគអេដស៍ថ្មីពី១១០០នាក់/ឆ្នាំ មកត្រឹម ៣០០នាក់/ឆ្នាំ គឺយើងត្រូវស្វែងយល់ និងស្វែងរក ១) នៅតំបន់ណា? គឺនៅតំបន់៣យ៉ាង និងរាជធានីភ្នំពេញ ២)តើក្រុមណា? គឺក្រុមយុវវ័យ ជាបុរសរួមភេទជាមួយបុរស ៣) តើធ្វើដូចម្តេចរកឱ្យឃើញ ១.១០០ ករណីឆ្លងថ្មី? គឺប្រើប្រាស់ទិន្នន័យ។ ក្រៅពីនេះគឺត្រូវរកឱ្យឃើញអ្នកផ្ទុកមេរោគអេដស៍ដែលមិនទាន់បានដឹងពីស្ថានភាពរបស់ខ្លួនចំនួនជាង ១០.០០០នាក់ទៀត ។

**ឯកឧត្តម** ក៏បានគូសបញ្ជាក់ពីសារសំខាន់នៃការប្រើប្រាស់រូបមន្ត Problem Driven Iterative adaptation (PDIA) ក្នុងការសម្របខ្លួនបន្តបន្ទាប់សំដៅដោះស្រាយបញ្ហា។ ចំពោះវង្វង់ទាំងបី (Three Cycles: Authority, Acceptance, Ability) បើកាលណាយើងពង្រីងវង្វង់ទាំងបីនេះកាន់តែធំឡើង យើងកាន់តែពង្រីកបាននូវកន្លែងសម្រាប់ទទួលយកនូវការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ចំពោះការងារបន្តដែលត្រូវធ្វើមាន៖

- ប្រព័ន្ធជាតិក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា (Country System on HIV response: One coordination body, One country framework (NSP), One M&E Framework)
- ការរៀបចំក្រុមការងារ Sustainability Technical Working Group on HIV Response
- បន្តការងារ ID Poor, Midterm Review NSP on Health (NCHADS), ការងារឥស្សរជនឆ្នើមថ្នាក់ជាតិ (APLF-CRC)
- ការងារត្រូវរៀបចំ Investment Case, Optima, AEM/Spectrum, National Policy to ending AIDS)

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់បន្ថែមស្តីពីទ្រឹស្តីថ្មីដែល **ឯកឧត្តមអនុប្រធាន** បានបង្ហាញក្នុងការដោះស្រាយបញ្ហានេះ គឺត្រូវតែរៀនសូត្របន្ថែមទាំងអស់គ្នា តែចំណុចសំខាន់គឺការអនុវត្តទៅបាន ឬមិនបានគឺទៅតាមលទ្ធភាព និងសមត្ថភាពជាក់ស្តែង ហើយអគ្គលេខាធិការដ្ឋានត្រូវពិនិត្យសិក្សាមើលលើការងារនេះ។

**ក) អនុសាសន៍ របស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖**

បន្ថែមលើអនុសាសន៍ និងការប្រគល់ការងារដូចមានខាងលើ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានបញ្ជាក់ពីតួនាទីរបស់លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ នៅតាមបណ្តាខេត្ត ត្រូវតែធ្វើការងារជាពហុវិស័យ ដោយផ្តោតលើការសម្រេចបានគោលដៅ ៩៥ ទី១។ ចំពោះគោលដៅ ៩៥ទី២ និង៩៥ទី៣ គឺដំណើរការបានល្អហើយដែលជាសកម្មភាពទទួលខុសត្រូវរបស់មជ្ឈមណ្ឌលជាតិ NCHADS ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានប្រគល់ការងារដល់ **ឯកឧត្តមអគ្គលេខាធិការ** ក្នុងការធ្វើការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការប្រើប្រាស់មូលនិធិសកល ថាតើរបៀបចំណាយនៅក្នុងមូលនិធិសកលអាច យកមកអនុវត្តសម្រាប់គម្រោងទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ (FTC) ដែរឬទេ ?។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានមានប្រសាសន៍ថា សមត្ថភាពមន្ត្រីរបស់អាជ្ញាធរជាតិយើងមួយចំនួននៅមានកម្រិត ដែលត្រូវបង្កើនការរៀនសូត្រ និងលើកកម្ពស់ការយកចិត្តទុកដាក់លើការងារដោយការទទួលខុសត្រូវមួយកម្រិតទៀត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានរំលឹកដល់ថ្នាក់ដឹកនាំ មន្ត្រីអគ្គលេខាធិការដ្ឋានទាំងអស់ត្រូវពិនិត្យមើលថាតើនៅមានការងារអ្វីខ្លះទៀតដែលមិនទាន់បានបំពេញ និងត្រូវតាមដានឱ្យដាប់លាប់ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានឯកភាពជាគោលការណ៍ចំពោះរបៀបវារៈទាំង៣ សម្រាប់កិច្ចប្រជុំពេញអង្គ សន្និបាតប្រចាំឆ្នាំ និងទិវាប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២២ ដោយត្រូវកែសម្រួលលើចំណុចប្រកាសហេតុ និងការគោរពទង់ជាតិ ។

អង្គប្រជុំ បានបញ្ចប់នៅវេលាម៉ោង ១១ និង៣០ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល។

ថ្ងៃសុក្រ ១១កើត ខែកក្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ត្រូវនឹងថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២

អ្នកធ្វើកំណត់ហេតុ

**វេជ្ជ. ទេព ណារុង**

បានពិនិត្យត្រឹមត្រូវ
អគ្គលេខាធិការ អ.ជ.ប.ជ.អ

**បណ្ឌិត ឈឹម ឃិនដារ៉ែត**

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ
ទេសរដ្ឋមន្ត្រីប្រធាន អ.ជ.ប.ជ.អ

**អៀង មូលី**